# ១២~ រឿង គ្រូ និង សិស្ស

មានរឿង១ដំណាលថា : មានភិក្ខុមួយអង្គគង់នៅវត្ត មានកូនសិស្សតែម្នាក់ឈ្មោះអាឆ្លូញ ។ អាឆ្លូញខិលណាស់ គ្រូល្ងង់ណាស់ឆោតច្រើន គ្មានឧបាសក ឧបាសិកាណារាប់អានយកចង្ហាន់ស្លាបារី ទៅប្រគេន ឬនិមន្តលោកនោះមកឆាន់ផ្ទះដល់ម្តងឡើយ លោកនោះក្រលំបាកពន់ពេក តែលោកមានដំរីមួយ ។

ថ្ងៃមួយលោកនោះពិចារណាថា "សព្វថ្ងៃនេះគ្មានឧបាសក ឧបាសិកា គេប្រគល់វត្ថុអ្វីឆាន់សោះ បើដូច្នោះគួរអញទិញវត្ថុផ្សេងៗយកមកទុកឆាន់កុំឲ្យលំបាក" ។ គិតដូច្នោះហើយក៏ប្រាប់កូនសិស្សថា "អាឆ្លូញឯងចាប់ដំរីមក ហើយឯងទៅផ្សារនឹងអញរកទិញវត្ថុផ្សេងៗយកមកទុកឆាន់" ។ កូនសិស្សទៅចាប់ដំរីបានមក គ្រូនិងសិស្សក៏ឡើងជិះដំរីទៅផ្សារ ។ លុះទៅដល់គ្រូប្រាប់កូនសិស្សថា "ឯងទិញវត្ថុអ្វីដែលទុកបានយូរមិនខូច" ។ អាឆ្លូញជាសិស្សក៏ទិញអំបិលមួយចុងច្រកការុងស្រេច ។ គ្រូឃើញសួរថា " ហេតុដូចម្តេចក៏ឯងទិញតែអំបិល មិនទិញត្រីឆ្អើរត្រីងៀតផង ?" ។ កូនសិស្សទូលថា " អំបិលទុកបានយូរ មិនចេះខូច បានជាខ្ញុំព្រះករុណាទិញ" ។ គ្រូឆោតល្ងង់ណាស់ក៏ស្ងៀម ។

គ្រូឡើងបរដំរីមកវិញ សិស្សវែកអំបិលដើរពីក្រោយ ដល់ពាក់កណ្តាលផ្លូវគ្រូមើលទៅសិស្ស ឮស្ងួរដងវែកដូចជាស្រួលក៏សួរថា "អាឆ្លូញ! អញមើលទៅឯងវែកអំបិលដូចជាស្រួលឬយ៉ាងណា ?" ។ សិស្សទូលថា "ព្រះករុណា! ស្រួលណាស់ហើយស្រាលផង" ។ លោកគ្រូប្រាប់សិស្សថា "ឯងជិះដំរីវិញអញវែកអំបិលដើរក្រោយ" ។ លោកគ្រូថាហើយ ចុះពីលើដំរីមក សិស្សក៏ឡើងជិះដំរីទៅ ។ លោកគ្រូប្រាប់ថា "ឯងបរដំរីទៅចាំអញម្លប់ឈើមុខ" ។ សិស្សបរដំរីទៅដល់ម្លប់ឈើក៏មិនឈប់ចាំគ្រូ បររហូតដល់វត្ត ។

លោកគ្រូវែកអំបិលដើរតាមក្រោយ ដោយអំបិលនោះធ្ងន់ណាស់ លោកគ្រូវែកឈប់ៗ បែរមើលទៅសិស្សមិនឃើញក៏គិតថា " ចាំក្រោយសឹម នាំសិស្សមកយក

" ហើយយកអំបិលទៅលាក់ក្នុងព្រៃ មុននឹងលាក់លោកគិតថា" ទីនេះបើប្រសិនជាមានគេដើរមកចំរកឃើញ គេនឹងយកអំបិលនេះអស់មិនខាន គួរតែរកទីណាដែលកំបាំងភ្នែកអ្នកទាំងពួង គឺមានតែក្នុងទឹកទើបគេមើលមិនឃើញ" ហើយក៏យកអំបិលទាំងពីរការុងទៅលាក់ទុកក្នុងទឹក ហើយដើរទៅ លុះដល់សួរសិស្សថា"ហេតុដូចម្ដេចក៏ឯងមិនចាំអញ ?" ។ សិស្សទូលថា"ខ្ញុំព្រះករុណាបរដរីមកប្រុងចាំលោកគ្រូដែរ តែដរីមិនព្រមចាំសោះ អង្វរដូចម្ដេចក៏វាមិនព្រម វាប្រឹងដើរដល់វត្តទើបឈប់" ។ សិស្សសួរគ្រូថា"លោកគ្រូទុកអំបិលឯណា ?" ។ គ្រូប្រាប់ថា"អញលាក់ទុកនៅទីឯណា អញកាច់ដើមឈូកដោតជាសំគាល់" ។ ព្រឹកឡើងនាំកូនសិស្សទៅយកអំបិលវិញ លុះដល់ប្រាប់សិស្សថា"អញលាក់ទុកក្នុងត្រពាំងនេះ" ។ សិស្សលាន់មាត់ថា "ម៉ែអើ ! វារលាយអស់ហើយ!" ។ អាផ្លូញក៏ចុះទៅយកអំបិលលើកការុងទាំងពីរឡើងរលាយអស់គ្មានសល់ ចំណាងដែលចងមាត់ការុងដាច់អស់ ឃើញឯត្រីកញ្ចុះមួយនៅក្នុងការុងនោះ ។ សិស្សទូលលោកគ្រូថា"មានត្រីកញ្ចុះមួយនៅក្នុងការុងវាស៊ីអំបិលអស់ហើយ" ។ យកត្រីនិងការុងប្រគេនគ្រូមើល ។ លោកគ្រូឃើញត្រីខឹងណាស់ក៏ទះកំផ្លៀងមុតដៃនឹងធ្មង់ត្រីជាប់ ។ ពិសត្រីចាប់ពើតឈឺខ្លាំងពេក លោកគ្រូថា"ឯងចាប់ត្រីដកធ្មង់វាឆាប់ត្បិតអញឈឺណាស់" ។ សិស្សក៏ចាប់ដកទាញស្ទើរតែមិនរួច ។ លុះដករួចឈាមហូរជាខ្លាំង ពិសត្រីរិតតែឈឺខ្លាំងឡើង លោកគ្រូនាំកូនសិស្សទៅវត្តវិញយកទាំងការុង និងត្រីកញ្ចុះទៅផង ដល់ទៅវត្តប្រាប់សិស្សថា"អាផ្លូញ ឯងដាំបាយមួយឆ្នាំង អាំងត្រីកញ្ចុះនេះឲ្យឆ្អិនជាឆាប់អញនឹងឆាន់" ។ លុះពិសអន់ចាប់ពើត លោកគ្រូក៏សំងំឈឹងលក់ទៅ ។

ឯអាផ្លូញក៏ដាំបាយអាំងត្រីឆ្អិន ហើយបរិភោគអស់ទុកតែបាយមួយពំនូកនិងឆ្អឹងត្រីក្នុងចានគ្រប តែវាគ្របមិនឲ្យជិត ។ លោកគ្រូភ្ញាក់ឡើងប្រាប់សិស្សថា"ឯងយកបាយនិង ត្រីមកឆាន់" អាផ្លូញក៏ធ្វើជាកិរិយាដូចជាទៅយកបាយប្រគេនគ្រូចេញមកវិញទូលថា"បាយនិងត្រីរុយកស៊ីអស់ទៅហើយ នៅសល់តែមួយពំនូក និង ឆ្អឹងត្រី " លោកគ្រូជឿឥតសង្ស័យដោយឆោតល្ងង់ក៏ឲ្យរំពាត់ផ្ដៅមួយមកសិស្សថា"ឯងវាយរុយកុំឲ្យវានៅលើកុដិ" អាផ្លូញជាសិស្សក៏វាយរុយមិនឈប់ ។ គ្រានោះមានរុយទុំច្រមុះគ្រូវាយទៅៗមិនត្រូវរុយ ត្រូវច្រមុះគ្របែកឈាមហូរខ្លាយ ។ សិស្សភ័យណាស់រត់ទៅដល់ផ្ទះនិយាយប្រាប់ឪពុកម្ដាយតាមរឿង ។ ឪពុកម្ដាយប្រាប់កូនឱ្យមកវត្តវិញ កូនប្រកែកមិនព្រមមក ។ លោកគ្រូទៅតាមក៏វាមិនហ៊ានមកដោយខ្លាចគ្រូវាយ ។

ថ្ងៃមួយលោកគ្រូ. តាំងពិធីសូត្រមន្តអាគមស្នេហ៍បន្ទន់ចិត្តសិស្សឲ្យមក ។ អាផ្លូញជាសិស្សបានដឹងថា គ្រូ តាំងពិធីសូត្រមន្តអាគមស្នេហ៍ដូច្នោះ ក៏មកវត្តវិញ ដើម្បីឲ្យគ្រូជឿថា ស្នេហ៍ពូកែ ។ លុះដល់វត្តវិញដើរលបៗចូលទៅឃើញគ្រូកំពុងតែអង្គុយសូត្រមន្តអាគមស្នេហ៍ ក៏សួរលោកថា"លោកគ្រូធ្វើអ្វី ?" ។ គ្រូកុហកថា"អញសូត្រមន្តអាគមបំបាំងខ្លួន ព្រោះអញទើបរៀនពីគេ" ។ ហើយលោកគ្រូគិតថា"ស្នេហ៍អញពូកែមែនបានជាសិស្សអញវាមក" ។ លុះព្រឹកឡើងសិស្សដាំបាយធ្វើម្ហូបស្រេច ទូលថា"ចង្ហាន់ឆ្អិនហើយ" ។ លោកគ្រូថា"បើដូច្នោះឯងលើកយកឲ្យអញឆាន់" ។ អាផ្លូញក៏លើកមកប្រគេន ធ្វើជាមើលមិនឃើញ ដាក់ថាសទៅលើក្បាលគ្រូៗស្រែកថា"អាផ្លូញ! ហេតុម្ដេចក៏យកថាសមកដាក់លើក្បាលអញ ?" ។ សិស្សទូលថា"ខ្ញុំព្រះករុណាមើលមិនឃើញ" ។ លោកគ្រូងាកចេញ អាផ្លូញក៏ដាក់លើក្បាលគ្រូទៀត ។ លោកគ្រូថា"អាឯងដាក់ថាសលើក្បាលអញទៀតហើយ" ។ សិស្សថា"ខ្ញុំព្រះករុណាសូមទោសព្រោះមើលមិនឃើញ" ។ លោកគ្រូជឿថា អញរៀនស្នេហ៍ៗពូកែប្រាកដ ឥឡូវអញកុហកវាថាតាំងពិធីមន្តអាគមបំបាំងខ្លួនវិញ ក៏ទៅជាពូកែគេមើលមិនឃើញប្រាកដមែន គួរខន្ទេញឱ្យចាំកុំឱ្យភ្លេច ។

អាផ្លូញលុះប្រគេនចង្ហាន់គ្រូៗ ឆាន់រួចហើយ វាលើកមកបរិភាគខ្លួនវា ។

ថ្ងៃក្រោយមានឧបាសកគេនិមន្តលោកគ្រូទៅឆាន់ឯផ្ទះ ។ អាផ្លូញទូលថា "បើលោកគ្រូនិមន្តទៅឆាន់ផ្ទះគេ កុំស្លៀកស្បង់ឲ្យចាស់ខូចឥតអំពើឃ្លុំតែចីពរបានហើយ គេមើលមិនឃើញទេ ត្បិតលោកគ្រូចេះមន្តអាគមបំបាំងខ្លួនពូកែណាស់ អ្នកណានឹងមើលឃើញ "គ្រូជឿក៏ធ្វើតាមពាក្យសិស្ស ។

លុះព្រឹកឡើងលោកគ្រូប្រាប់សិស្សថា "ឯងតាមអញទៅឆាន់ឯផ្ទះឧបាសក" រួចលោកឃ្លុំតែចីពរមិនស្លៀកស្បង់ដោយគិតថា "ឃ្លុំតែចីពរបានហើយ ព្រោះមន្តអាគមអញពូកែណាស់ នរណានឹងមើលកេរ្តិ៍ខ្មាសឃើញ" រួចនាំកូនសិស្សទៅ ។

លុះទៅដល់ឧបាសកនិមន្តឡើងលើផ្ទះហើយ គេលើកចង្ហាន់មក ដើម្បីប្រគេនលោកឆាន់ ដោយលោកមិនបានស្លៀកស្បង់ អង្គុយមិនស្រួលងាកឆ្វេងងាកស្តាំក៏លេចកេរ្តិ៍ខ្មាស(១) កណ្តាលវាល ។ ឧបាសកឃើញដូច្នោះគេក៏នាំគ្នាសើចហោរលាន់ ។ លោកគ្រូពុំទាន់បានឆាន់ចង្ហាន់មានចិត្តខ្មាសគេណាស់ ក៏ចុះពីផ្ទះត្រឡប់មកវត្តវិញ ជេរបន្ទោសសិស្សថា "អាឯងមិនឱ្យអញស្លៀកស្បង់ ឥឡូវអញខ្មាសគេណាស់" អាផ្លូញទូលថា "លោកគ្រូកុំខ្ចាល់នឹងខ្ញុំព្រះករុណា រឿងនេះប្រហែលជាខុសត្រណមទេឬ ?" ។ លោកគ្រូសួរថា "ឯងឃើញអញខុសត្រណមដូចម្តេច ?" ។ អាផ្លូញសួរថា "កាលណាគ្រូនិមន្តទៅឆាន់ផ្ទះឧបាសក និមន្តទៅផ្លូវណា ?" ។ លោកគ្រូប្រាប់ថា "អញកាលទៅចេញផ្លូវកើត" ។ សិស្សថា "ឱ! ច្បាស់ជាលោកគ្រូខុសត្រណមហើយ " ។ ថ្ងៃមុនលោកគ្រូប្រាប់ខ្ញុំព្រះករុណាថា "បើរៀនមន្តអាគមទាំងពួងត្រូវឱ្យតមស៊ីផ្លែស្ពឺ សូម្បីតែមុជក្រោមដើមស្ពឺក៏មិនបាន វាសាបមន្តអាគម ឥឡូវលោកគ្រូមុជក្រោមដើមស្ពឺបានជាខុសត្រណម សាបអាគមអស់ ហេតុនេះបានជាគេឃើញកេរ្តិ៍ខ្មាសលោកគ្រូ" ។ លោកគ្រូបានស្តាប់ដូច្នោះហើយ ក៏ថា "ឱ! អាផ្លូញអញភ្លេចតមបានជាយ៉ាងហ្នឹង ឯងថានោះពិតប្រាកដហើយ" ។ លោកគ្រូនោះដោយឆោតល្ងង់ក៏ជឿជាក់ឥតសង្ស័យ ។ តាំងពីនោះមកអាផ្លូញជាសិស្សនៅបម្រើគ្រូដោយសុខសប្បាយ ។

## ស្លូតស្លាប់ ទៀចទេរមានភព្វ អាយុយឺនយូរ

(១). ហៅតែ ខ្ទាស ខទេក៏បាន ។